**រាជបណ្ឌិត្យសភាកម្ពុជា**
**វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ**

*លទ្ធផលគម្រោងសិក្សាស្រាវជ្រាវ ស្តីពី*

# ចម្លាក់អប្សរានៅប្រាសាទអង្គរវត្តៈ សិល្បៈតែងលម្អសក់និងការរចនាសំពត់






*សមាសភាពអនុវត្តគម្រោង៖*

*ឯកឧត្តមបណ្ឌិត នូ ចាន់សុភី*

- *បណ្ឌិត ធុយ ចាន់ធួន*
- *លោកស្រី ម៉ិល វាសនា*
- *លោក ទិន ទីណា*
- *លោក ហឿង សុធារស់*
- *លោក ប្រែង ពិសិដ្ឋ*
- *លោក ចាន់ សោភ័ន*
- *លោកស្រី សរ សិលា*
- *លោកស្រី យ៉ាន់ វិភារតន៍*
- *លោក ឡេង សត្យា*


**ខែកុម្ភៈ ២០២០**

## លទ្ធផលគម្រោងសិក្សាស្រាវជ្រាវ ស្ដីពី

# ចម្លាក់អប្សរានៅប្រាសាទអង្គរវត្ត៖ សិល្បៈតែងលម្អសក់និងការរចនាសំពត់

### សេចក្ដីផ្ដើម

ការសិក្សាស្រាវជ្រាវស្ដីពី «**ចម្លាក់អប្សរានៅប្រាសាទអង្គរវត្ត៖ សិល្បៈតែងលម្អសក់និងការរចនាសំពត់**» ជាគម្រោងស្រាវជ្រាវមួយដែលវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជា ទទួលការអនុញ្ញាតជាគោលការណ៍សម្រាប់ការសិក្សាស្រាវជ្រាវរយៈពេលពីរឆ្នាំគឺ ឆ្នាំ២០១៩ និងឆ្នាំ២០២០។ គម្រោងនេះមានគោលបំណងធ្វើការសិក្សាស្រាវជ្រាវ ១-កំណត់លក្ខណៈរូបនៃចម្លាក់អប្សរា(ចម្លាក់រូបស្រីដែលឆ្លាក់នៅប្រាសាទអង្គរវត្ត មានដូចជា អប្សរា ទេពស្រី និង អ្នករាំ) ដើម្បីធ្វើការសិក្សានិងញែកឱ្យច្បាស់ពីលក្ខណៈខុសគ្នានៃចម្លាក់រូបស្រីទាំងនោះ ២-សិក្សាលម្អិតលើរូបអប្សរានីមួយៗពីសិល្បៈតែងលម្អលើក្បាល(មកុដ ...) ក្បាច់លម្អសក់ ក្បាច់សម្លៀកបំពាក់(ផ្ដោតលើសំពត់) ៣-កំណត់និងរកប្រភេទរចនាបថដោយឡែកៗពីគ្នានៃគ្រឿងលម្អសក់និងការរចនាសំពត់ ដោយបែងចែកជាក្រុមក្បាច់ធំៗក្នុងចំណោមចម្លាក់អប្សរាទាំងអស់ដែលបានរកឃើញ ៤-ធ្វើបញ្ជីសារពើភណ្ឌរូបអប្សរាដែលកំណត់ក្នុងការស្រាវជ្រាវលម្អិត ៥-ចងក្រងឯកសាររូបភាពអប្សរជាឯកសារសំណេរនិងវីដេអូ។

ក្នុងការអនុវត្តគម្រោងនេះ វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈនៃរាជបណ្ឌិត្យសភាកម្ពុជាបានសហការយ៉ាងពេញលេញជាមួយអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ទាំងផ្នែកការងាររដ្ឋបាលនិងផ្នែកការងារបច្ចេកទេស។ ជាក់ស្ដែងក្នុងឆ្នាំ២០១៩កន្លងទៅ មន្ត្រីអាជ្ញាធរជាតិអប្សរាមានលោក **ទិន ទីណា** និង លោក **ឡេង សត្យា** បានជួយដោយផ្ទាល់លើការងាររដ្ឋបាលនិងការងារបច្ចេកទេសនៅតំបន់អង្គរ ក្រោមការសម្របសម្រួលពីឯកឧត្ដមបណ្ឌិត **ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា។ ចំណែកលោក ចាន់ សោភ័ន សាស្ត្រាចារ្យមហាវិទ្យាល័យសិល្បៈសូនរូប បានចូលរួមយ៉ាងសកម្មលើការងារបច្ចេកទេសផ្នែកការសិក្សាពីក្បាច់សិល្បៈលម្អលើចម្លាក់និងការគូររូបចម្លង និងបានចុះទៅសិក្សាដល់ទីតាំងផ្ទាល់ ក្រោមការសម្របសម្រួលពីឯកឧត្ដមបណ្ឌិត **ហេង សុផាឌី** សាកលវិទ្យាធិការសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ ជាមួយគ្នានេះ ក្រុមការងារស្រាវជ្រាវក៏ទទួលបានការសម្របសម្រួលនិងការយកចិត្តទុកដាក់ពីមន្ត្រីប្រចាំការនៅប្រាសាទអង្គរវត្តផងដែរ។

ក្នុងឆ្នាំ២០១៩កន្លងទៅនេះ ការអនុវត្តគម្រោងបានផ្ដោតជាចម្បងលើ**សិល្បៈតែងលម្អសក់**របស់ចម្លាក់អប្សរា តាមរយៈការងារមួយចំនួនគឺ សិក្សាឯកសារពាក់ព័ន្ធ ជួបពិភាក្សាជាមួយអ្នកជំនាញ ចុះថតរូប ចុះលេខកូដរូប កំណត់អត្តសញ្ញាណគ្រឿងលម្អលើកេសា គូរគំនូរចម្លង និង ពិពណ៌នាសិល្បៈចម្លាក់ ជាដើម។ ជាលទ្ធផលក្រុមការងារបានថតរូបអប្សរានិងចុះលេខកូដរូបអប្សរាចំនួន**១៤៧១រូប** បានពណ៌នាសិល្បៈតែងលម្អក្បាលនិងសក់អប្សរាចំនួន**៦៩៦រូប** និង បានគូរគំនូរចម្លងរូបអប្សរាចំនួន**៣៦រូប**។

# កម្រងរូបភាពនៃកិច្ចប្រជុំពិគ្រោះយោបល់ និងការជួបសម្ភាសន៍ជាមួយអ្នកជំនាញ




កិច្ចប្រជុំពិភាក្សារបស់ក្រុមការងារមុនពេលចុះអនុវត្តគម្រោងនៅវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ




ជំនួបពិភាក្សាជាមួយលោក ឡុង រី និងលោក ឡេង សត្យា មន្ត្រីអាជ្ញាធរជាតិអប្សរា នៅខេត្តសៀមរាប




កិច្ចប្រជុំពិភាក្សាកំណត់អត្តសញ្ញាណគ្រឿងតុបតែងលម្អលើក្បាលនៃរូបចម្លាក់អប្សរា
ជាមួយមន្ត្រីជំនាញមកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៅវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ



ជំនួបពិភាក្សាជាមួយឯ.ឧ. ហ៊ឹ ចិន្តា អ្នកជំនាញក្បាច់ចម្លាក់ នៅវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ



ជំនួបពិភាក្សាជាមួយឯ.ឧ.បណ្ឌិត លី វណ្ណា ទីប្រឹក្សាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នៅខេត្តសៀមរាប

## កម្រងរូបភាពនៃការចុះសិក្សាស្រាវជ្រាវនៅប្រាសាទអង្គរវត្ត



ក្រុមការងារជួបពិគ្រោះយោបល់ជាមួយឯកឧត្តមបណ្ឌិត ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា នៅប្រាសាទអង្គរវត្ត





សកម្មភាពក្រុមស្រាវជ្រាវចុះសិក្សាផ្ទាល់និងថតរូបនៅប្រាសាទអង្គរវត្ត

 

ក្រុមស្រាវជ្រាវថតរូបអប្សរានិងចុះលេខកូដអប្សរានៅប្រាសាទអង្គរវត្ត



សកម្មភាពក្រុមស្រាវជ្រាវធ្វើការផ្ទៀងផ្ទាត់
រូបគំនូរចម្លងនិងចម្លាក់អប្សរាពិតនៅប្រាសាទអង្គរវត្ត



សកម្មភាពក្រុមស្រាវជ្រាវចុះសិក្សារូបអប្សរា
នៅសារមន្ទីរអភិរក្សអង្គរ

# ការពិពណ៌នាចម្លាក់អប្សរ

ខាងក្រោមនេះជាការលើកយករូបអប្សរខ្លះៗមកបរិយាយពីសិល្បៈតែងលម្អរលើក្បាលនិងសក់៖

**ចម្លាក់អប្សរផែន** A4



Code: A4-I-1-1.#12-1 (1)

ចម្លាក់អប្សរ Code: A4-I-1-1.#12-1 (1)នេះមានគ្រឿងលម្អតាក់តែងលើក្បាលដោយមកុដកំពូលមួយ។ មកុដកំពូលមួយនេះផ្សំឡើងដោយក្បាំងនិងកំពូលមួយ៖

- ក្បាំងមានចង្វាយក្បាច់បីខ្សែ
- កំពូលមានពិននិងស្នៀតពិន( ផ្កាមូលៗ )។ ពិនមានទម្រង់ជារួតនិងមានចំនួនបួនរួត។ នៅតាមគល់ពិនមានស្នៀតពិនធំមួយដែលផ្នែកខាងលើរចនាលម្អដោយក្បាច់សន្លឹករាងត្រីកោណ។

មកុដអប្សរនេះមានគ្រឿងលម្អតាក់តែងបន្ថែមដោយស្នៀតផ្កាទម្រង់ពីរផ្សេងគ្នាសៀតនៅសងខាងពិនតាមលំដាប់ ដោយនៅខាងឆ្វេងពិនមានចំនួនបួន និងនៅខាងស្តាំពិនមានចំនួនប្រាំ។ នៅសងខាងក្បាំងផ្នែកខាងក្រោមមានសៀតស្នៀតរំយោលទម្រង់ក្បាច់ផ្កាស្លាឬផ្កាដូងមួយៗផងដែរ។



Code: A4-O-1-1.#8-1 (1)

ចម្លាក់អប្សរ Code: A4-O-1-1.#8-1 (1)នេះ មានគ្រឿងតាក់តែងលម្អលើក្បាលដោយ**មកុដកំពូលមួយ**។ មកុដកំពូលមួយនេះផ្សំឡើងដោយក្បាំងនិងកំពូលមួយ៖

- ក្បាំងមានចង្វាយក្បាច់បីខ្សែ
- កំពូលមានពិននិងស្មៀតពិន(ផ្កាម្ទូលៗ)។ ពិនមានទម្រង់ជារួតដែលមានប្រាំមួយរួត ហើយមានស្មៀតពិនមួយធំដោតនៅចំកណ្ដាលជាប់នឹងគល់ពិនលើក្បាំងមកុដ។ នៅសងខាងស្មៀតពិនធំមួយនេះមានស្មៀតពិនលម្អពីចំហៀងមួយៗទៀត។ នៅលើស្មៀតពិនធំនេះមានស្មៀតសន្លឹកពិនចំនួនពីរសៀតនៅតាមគល់រួតបន្តបន្ទាប់គ្នា។

មកុដនេះមានគ្រឿងលម្អតាក់តែងបន្ថែមដោយស្មៀតសន្លឹកនៅចំហៀងសងខាងកំពូលចំនួនបី និងស្មៀតរំយោលសងខាងចំនួនពីរ។



Code: A4-O-1-1.#1-1 (1)

ចម្លាក់អប្សរ Code: A4-O-1-1.#1-1(1) នេះមានគ្រឿងលម្អតាក់តែងលើក្បាលដោយ**មកុដកំពូលបី**។ មកុដកំពូលបីនេះផ្សំឡើងដោយក្បាំងនិងកំពូលចំនួនបី៖

- ក្បាំងមានចង្វាយក្បាច់បីខ្សែ
- កំពូលនីមួយៗមានពិន និងស្នៀតពិន( ផ្កាមូលៗ )។ ពិននីមួយៗមានទម្រង់ជារួត( ថ្នាក់ ) ដែលពិននៅកណ្ដាលមានចំនួនប្រាំបីរួតនិងពិនខាងៗមានចំនួនប្រាំពីររួត។ នៅតាមតួពិននីមួយៗមានលំអដោយស្នៀតសន្លឹកពិនមួយៗ។ ស្នៀតពិនមានចំនួនបីនិងមានមួយថ្នាក់ ហើយសៀតនៅតាមគល់ពិនមួយៗ។

មកុដនេះមានគ្រឿងលម្អតាក់តែងបន្ថែមដោយស្នៀតផ្កាតូចៗ( ស្រដៀងនឹងស្នៀតពិន )នៅតាមចំហៀងគល់ពិន និងមានស្នៀតរំយោលនៅចំហៀងខាងឆ្វេងបី និងស្នៀតរំយោលនៅចំហៀងខាងស្ដាំពីរ។ ស្នៀតរំយោលនេះរចនាក្បាច់ទម្រង់ខុសៗគ្នា។



Code: A4-I-8-3.#4-1 (1)

ចម្លាក់អប្សរ Code: A4-I-8-3.#4-1(1)នេះមានគ្រឿងលម្អតាក់តែងលើក្បាលដោយ**មកុដកំពូលប្រាំ**។ មកុដកំពូលប្រាំនេះផ្សំឡើងដោយក្បាំងនិងកំពូលចំនួនប្រាំ៖

- ក្បាំងមានចង្វាយក្បាច់ចំនួនបួនខ្សែ
- កំពូលនីមួយៗមានពិននិងស្នៀតពិន( ផ្កាមូលៗ )។ ពិននីមួយៗមានទម្រង់ជាផ្កា។ ស្នៀតពិនសរុបមានចំនួនប្រាំ ដោយស្នៀតពិនមួយសៀតនៅគល់ពិនមួយ។ ស្នៀតពិនទាំងនេះត្រូវសៀតជាពីរថ្នាក់ ដោយថ្នាក់ទី១( ថ្នាក់ក្រោម )មានសៀតស្នៀតពិនចំនួនបី( ពិនកណ្តាលនិងពិននៅខាង ) និងថ្នាក់ទី២( ថ្នាក់លើ )មានសៀតស្នៀតពិនចំនួនពីរ( ពិនសងខាងពិនកណ្តាល )។

មកុដនេះមានគ្រឿងលម្អតាក់តែងបន្ថែមដោយស្នៀតរំយោលនៅសងខាងចំនួនបីរចនាក្បាច់ក្នុងទម្រង់ពីរផ្សេងគ្នា។



Code: A4-I-8-3.#21-1 (1)

ចម្លាក់អប្សរ Code:A4-I-8-3.#21-1(1)នេះមានគ្រឿងលម្អតាក់តែងលើក្បាលដោយ**មកុដកំពូលប្រាំ**។ មកុដកំពូលប្រាំនេះផ្សំឡើងដោយក្បាំងនិងកំពូលចំនួនប្រាំ៖

- ក្បាំងមានចង្វាយក្បាច់ចំនួនបីខ្សែ
- កំពូលនីមួយៗមានពិននិងស្នៀតពិន(ផ្កាម្ទូលៗ)។ ពិននីមួយៗមានទម្រង់ជារូត(ស្រដៀងក្បាច់កេសរ)។ ស្នៀតពិនសរុបមានចំនួនប្រាំបីនិងមានបីថ្នាក់ ដែលថ្នាក់ទីមួយមានស្នៀតពិនចំនួនប្រាំ ថ្នាក់ទីពីរមានស្នៀតពិនចំនួនពីរ និងថ្នាក់ទីបីមានស្នៀតពិនចំនួនមួយ។ នៅតាមពិននីមួយៗមានស្នៀតពិនមួយ លើកលែងនៅពិនកណ្តាលមានស្នៀតពិនចំនួនពីរ និងមានស្នៀតពិនមួយៗសៀតនៅចំហៀងសងខាង។

មកុដអប្សរនេះមានគ្រឿងលម្អតាក់តែងបន្ថែមដោយស្នៀតរំយោលសងខាងចំនួនបី រចនាក្បាច់ក្នុងទម្រង់ដូចគ្នា(អាចជាផ្កាក្រងឬផ្ការំយោល)។

**ចម្លាក់អប្សរផែន A3**



Code: A3-O-1-1.#1-1 (2)

ចម្លាក់អប្សរ Code: A3-O-1-1.#1-1 (2) នេះមានម៉ូតសក់ផ្នួងមួយច្បូតឡើងលើ និងពត់ចុងសក់រាងកោងមកចំហៀងខាងស្តាំ។ ម៉ូតសក់អប្សរនេះមានតាក់តែងលំអដោយស្នៀតផ្កាចំនួនប្រាំបីសៀតពីក្រោយផ្នួងសក់ ដែលនៅក្នុងនោះមានស្នៀតផ្កាចំនួនបួន( កណ្តាល )សៀតឡើងលើ ហើយស្នៀតផ្កាទាំងបួនទៀតនៅចំហៀងសងខាង ដែលម្ខាងៗមានស្នៀតផ្កាចំនួនពីរ សៀតពត់ទម្លាក់ចុះ។



Code: A3-O-1-1.#2-2 (4)

ចម្លាក់អប្សរ Code: A3-O-1-1.#2-2 (4) នេះមានម៉ូតសក់ផ្នួងមួយច្បូតទម្លាក់សក់មកចំហៀងខាងឆ្វេង និងមានស្នៀតផ្កា( ស្រដៀងនឹងផ្កាចំប៉ា )ចំនួនប្រាំមួយ លម្អសក់នៅតាមផ្នួង។ ស្នៀតផ្កាទាំង

អស់សៀតពីខាងក្រោយផ្នួងហើយសៀតញែកចេញពីគ្នាជាពីរ។ នៅចំហៀងផ្នួងសក់ខាងស្តាំមានស្នៀតផ្កាចំនួនបួន(ផ្កាពីរសៀតពីលើនិងផ្កាពីរទៀតសៀតពត់ទម្លាក់ចុះ)។ ចំណែកនៅចំហៀងផ្នួងសក់ខាងឆ្វេង មានស្នៀតផ្កាចំនួនពីរសៀតពីលើ។

**ចម្លាក់អប្សរនៅជាន់ព្រះពាន់**



Code: A-CG-1.#1-1 (2)

ចម្លាក់អប្សរ Code: A-CG-1.#1-1 (2) នេះមានគ្រឿងលំអតុបតែងលើក្បាលដោយមកុដកំពូលបី។ មកុដកំពូលបីនេះផ្សំឡើងដោយក្បាំងនិងកំពូលចំនួនបី៖

- ក្បាំងមានចង្វាយក្បាច់ចំនួនប្រាំខ្សែ

- កំពូលនីមួយៗមានពិននិងស្នៀតពិន។ កំពូលកណ្តាលមានពិនមួយនិងស្នៀតពិនបី រីឯកំពូលសងខាងមានពិនមួយនិងស្នៀតពិនពីរៗ។ ពិននីមួយៗមានទម្រង់ជាផ្កា ហើយស្នៀតពិនមានចំនួនប្រាំពីរនិងមានបីថ្នាក់ ដែលនៅថ្នាក់ទីមួយមានស្នៀតពិនចំនួនបី ហើយថ្នាក់ទីពីរក៏មានស្នៀតពិនចំនួនបីដែរ រីឯនៅថ្នាក់ទីបីមានស្នៀតពិនចំនួនតែមួយ។

មកុដនេះមានគ្រឿងលម្អតាក់តែងដោយស្នៀតរំយោលនៅសងខាងចំនួនពីរ។ នៅកំពូលចំហៀងខាងឆ្វេងមានឆ្លាក់បង្ហាញពីកាយវិការអប្សរកំពុងលើកដៃសៀតរុក្ខជាតិផ្កាមួយទងបន្ថែម។



Code: A-CG-1.#2-4 (4)

ចម្លាក់អប្សរ Code: A-CG-1.#2-4 (4) នេះមានគ្រឿងលម្អតាក់តែងលើក្បាលដោយមកុដកំពូលបី។ មកុដកំពូលបីនេះផ្សំឡើងដោយក្បាំងនិងកំពូលចំនួនបី៖

- ក្បាំងមានចង្វាយក្បាច់ចំនួនបួនខ្សែ

- កំពូលនីមួយៗមានពិនមួយនិងស្នៀតពិនមួយ។ ពិននីមួយៗមានទម្រង់ជារួត និងមានចំនួនបីរួតដូចៗគ្នា។ ស្នៀតពិនមានចំនួនបីនិងមានតែមួយថ្នាក់ ហើយសៀតនៅតាមគល់ពិននីមួយៗ។

មកុដនេះមានគ្រឿងលម្អតាក់តែងបន្ថែមដោយស្នៀតរំយោលសងខាងចំនួនបី រចនាក្បាច់ទម្រង់ដូចគ្នា។



Code: A-CG-1.#4-1 (4)

ចម្លាក់អប្សរ Code: A-CG-1.#4-1 (4) នេះមានម៉ូតសក់ផ្នួងពីរ(បួងទន្សាយ) ហើយច្បូតពត់ចុងសក់ទល់គ្នា។ សក់ខាងមុខប្រហែលកាត់សក់ខ្លី ហើយសិតគាស់ឡើងលើ។

ម៉ូតសក់អប្សរនេះមានស្នៀតផ្កាចំនួនប្រាំក្នុងទម្រង់ផ្កាបីប្រភេទដោយឡែកគ្នា (ប្រភេទផ្ការចនាក្បាច់ស្រដៀងនឹងទម្រង់ផ្កាស្លាឬផ្កាដូងមានចំនួនពីរ ប្រភេទរុក្ខជាតិផ្កាជាមែកមានមួយ និងប្រភេទផ្កាជារូតរបៀបជាពិនមានចំនួនពីរ)។ នៅតាមគល់ផ្នួងនីមួយៗមានវត្ថុលម្អជាកម្រងម៉្យាងនៅព័ទ្ធជុំវិញ។

**ចម្លាក់អប្សរផែន** A2



Code: A2-I-1-1.#8-1 (1)

ចម្លាក់អប្សរ Code: A2-I-1-1.#8-1(1)នេះមានគ្រឿងតាក់តែងលម្អលើក្បាលដោយមកុដកំពូលបី។ មកុដកំពូលបីនេះផ្សំឡើងដោយក្បាំងនិងកំពូលចំនួនបី៖

- ក្បាំងមានចង្វាយក្បាច់ចំនួនបួនខ្សែ
- កំពូលនីមួយៗមានពិនមួយនិងស្នៀតពិនមួយ។ ពិននីមួយៗមានទម្រង់ជាផ្កា។ ស្នៀតពិនមានចំនួនបីនិងមានមួយថ្នាក់ ហើយសៀតនៅតាមគល់ពិននីមួយៗ។

មកុដនេះមានគ្រឿងលម្អតាក់តែងបន្ថែមដោយស្នៀតរំយោលនៅចំហៀងសងខាងចំនួនបីៗ។ ចម្លាក់អប្សរនេះបានបង្ហាញនូវកាយវិការកំពុងលើកដៃសៀតផ្កាមួយធំ ចេញពីចំហៀងខាងឆ្វេង។



Code: A2-I-1-2.#1-2 (2)

ចម្លាក់អប្សរ Code: A2-I-1-2.#1-2 (2) នេះមានគ្រឿងលម្អតាក់តែងលើក្បាលដោយមកុដកំពូលបី។ មកុដកំពូលបីនេះផ្សំឡើងដោយក្បាំងនិងកំពូលចំនួនបី៖

- ក្បាំងមានចង្វាយក្បាច់ចំនួនបីខ្សែ

- កំពូលនីមួយៗមានពិនមួយនិងស្នៀតពិនមួយ។ ពិននីមួយៗមានទម្រង់ជារួត ដែលនៅពិនកណ្ដាលមានចំនួនបីរួត ចំណែកពិនសងខាងមានចំនួនពីររួត។ ស្នៀតពិនមានចំនួនបីនិងមានមួយថ្នាក់ ហើយសៀតនៅតាមគល់ពិននីមួយៗ។

មកុដនេះមានគ្រឿងលម្អតាក់តែងបន្ថែមដោយស្នៀតរំយោលនៅចំហៀងសងខាងចំនួនពីរ រចនាក្បាច់ទម្រង់ដូចៗគ្នា(ទម្រង់ផ្កាស្លាឬផ្កាដូង) ដែលស្នៀតរំយោលមួយនៅចំហៀងខាងស្ដាំមានធ្លាក់បង្ហាញពីរកាយវិការអប្សរកំពុងសៀត។



Code: A2-I-2-2.#6-2 (2)

ចម្លាក់អប្សរ Code: A2-I-2-2.#6-2 (2) នេះមានម៉ូតសក់បួងពីរ(បួងទន្សាយ) និងបូតសក់ចេញពីផ្គួងនីមួយៗទម្លាក់ចុះសងខាង។ ចម្លាក់អប្សរនេះមានសៀតផ្កាតាក់តែងលម្អសក់សរុបចំនួនប្រាំបីក្នុងទម្រង់ផ្កាប្រហែលបីប្រភេទដោយឡែកគ្នា (ទម្រង់ផ្កាមានទ្រនុងឬស្រទាប់ធំៗមានចំនួនពីរ ទម្រង់ផ្កាមានទ្រនុងឬស្រទាប់តូចៗមានចំនួនបួន និងទម្រង់ផ្កាមានឆ្លាក់ក្បាច់ទម្រង់ផ្កាស្លាឬផ្កាដូងមានចំនួនពីរ)។ នៅជុំវិញផ្គួងនីមួយៗមានរចនាលម្អដោយខ្សែរំយោលសន្លឹកវែងៗគ្របលើសក់។

**ចម្លាក់អប្សរាផែន** A1



Code: A1-O-1-1.#2-1 (2)

ចម្លាក់អប្សរ Code: A1-O-1-1.#2-1 (2) នេះមានគ្រឿងលម្អតាក់តែងលើក្បាលដោយមកុដកំពូលបី។ មកុដកំពូលបីនេះផ្សំឡើងដោយក្បាំងនិងកំពូលចំនួនបី៖

- ក្បាំងមានចង្វាយក្បាច់ចំនួនបួនខ្សែ

- កំពូលនីមួយៗ មានពិនមួយនិងស្នៀតពិនមួយ(ផ្កាមូលៗ)។ ពិននីមួយៗមានទម្រង់ជាផ្កា។ ស្នៀតពិនមានចំនួនបីនិងមានមួយថ្នាក់ ហើយសៀតនៅតាមគល់ពិននីមួយៗ។

មកុដនេះមានគ្រឿងលម្អតាក់តែងបន្ថែមដោយស្នៀតរំយោលនៅសងខាងចំនួនពីរ រចនាក្បាច់ទម្រង់ដូចគ្នា។



Code: A1-O-1-1.#8-1 (2)

ចម្លាក់អប្សរ Code: A1-O-1-1.#8-1(2) នេះមានគ្រឿងលម្អតាក់តែងលើក្បាលដោយមកុដកំពូលបី។ មកុដកំពូលបីនេះផ្សំឡើងដោយក្បាំងនិងកំពូលចំនួនបី៖

- ក្បាំងមានចង្វាយក្បាច់ចំនួនបីខ្សែ

- កំពូលនីមួយៗ មានពិនមួយនិងស្នៀតពិនមួយ(ផ្កាមូលៗ)។ ពិននីមួយៗមានទម្រង់ជាផ្កា។ ស្នៀតពិនមានចំនួនបីនិងមានមួយថ្នាក់ ហើយសៀតនៅតាមគល់ពិននីមួយៗ។

មកុដនេះមានគ្រឿងលម្អតាក់តែងបន្ថែមដោយស្នៀតរំយោលនៅសងខាងសរុបចំនួនដប់ រចនាក្បាច់ក្នុងទម្រង់ដោយឡែកគ្នា(ស្នៀតរំយោលម្ខាងមួយខាងលើរចនាជាទ្រនុងធ្នូតឬជាស្រទាប់ ស្នៀតរំយោលចំនួនបីទៀតនៅបន្ទាប់រចនាក្បាច់ទម្រង់ផ្កាស្លាឬផ្កាដូង ចំណែកស្នៀតរំយោលមួយទៀតនៅខាងក្រោមរចនាជាខ្សែមួយមានភ្ជាប់សន្លឹកមួយនៅខាងចុងខ្សែ។

## ខាងក្រោមនេះ ជាចម្លាក់អប្សរខ្លះៗ ដែលបានគូរចម្លងតាមច្បាប់ដើមជារូបគំនូរ






Code: A4-O-1-1. #4-1 (2)





Code: A4-O-1-1.#4-2 (2)




Code: A4-O-1-1. #5-2 (2)

## សេចក្តីសន្និដ្ឋាន

តាមរយៈការអនុវត្តគម្រោងសិក្សាស្រាវជ្រាវស្តីពី «ចម្លាក់អប្សរានៅប្រាសាទអង្គរវត្ត៖ សិល្បៈតែងលម្អសក់និងការរចនាសំពត់» ក្នុងឆ្នាំ២០១៩កន្លងមក យើងទើបនឹងបានធ្វើការសិក្សាពិពណ៌នាលើសិល្បៈតែងលម្អលើក្បាលនិងសក់បានមួយចំនួន ដែលមានទម្រង់ផ្សេងៗគ្នាបង្កប់ដោយសិល្បៈសូន្យរូបខ្មែរកម្រិតខ្ពស់ និងពោរពេញដោយទេពកោសល្យប្រកបដោយស្នាដៃវិចិត្រថែមទៀត។ ចំណែកសិល្បៈនៃការរចនាសំពត់មិនទាន់បានធ្វើការសិក្សាពិពណ៌នានៅឡើយ។

តាមរយៈការចុះទៅសិក្សាស្រាវជ្រាវផ្ទាល់ យើងសង្កេតឃើញថា ចម្លាក់អប្សរមួយចំនួនធំបានខូចខាតទម្រង់ដើមច្រើន ជាពិសេសនៅផ្នែកខាងក្រោមនៃដងខ្លួន។ ការខូចខាតនេះគឺបណ្តាលមកពីកត្តាផ្សេងៗ ដូចជាកត្តាធម្មជាតិ កត្តាមនុស្ស និងកត្តាអាយុកាល(ជាង៨០០ឆ្នាំ)។ ហេតុនេះ ការសិក្សាពិពណ៌នាចម្លាក់អប្សរជំហានទី១នេះ គឺជាផ្នែកដ៏សំខាន់មួយនៃការអភិរក្សចម្លាក់អប្សរ ដោយការពិពណ៌នានេះ គឺបានកត់សម្គាល់និងបញ្ជាក់ពីអត្តសញ្ញាណនៃក្បាច់ចម្លាក់របស់រូបចម្លាក់អប្សរនីមួយៗក្នុងកម្រិតដែលអាចធ្វើទៅបាន។